# ការសម្អាតអតីតកាល

២ករ.៥:១៧ បានជាបើអ្នកណានៅក្នុងព្រះគ្រិស្ត នោះឈ្មោះថាបានកើតជាថ្មីហើយ អស់ទាំងសេចក្តីចាស់បានកន្លងបាត់ទៅ...។

## ការសម្អាតអតីតកាល

បន្ទាប់ពីមនុស្សម្នាក់បានសង្គ្រោះហើយ របៀបរស់នៅចាស់ និងការប្រព្រឹត្តចាស់របស់គាត់ គួរតែមកដល់ទីបញ្ចប់ដែរ ។ មុនពេលគាត់ទទួលសេចក្តីសង្គ្រោះ គាត់ជាមនុស្សមានបាប រស់នៅក្នុងបាប ជាមនុស្សនៃការបង្កើតចាស់ និងប្រព្រឹត្តតាមរបៀបនៃការបង្កើតចាស់ ប៉ុន្តែពេលដែលគាត់បានសង្គ្រោះ ឥឡូវនេះគាត់បានក្លាយជាមនុស្សនៃការបង្កើតថ្មី ជាមួយនឹងជីវិតនៃការបង្កើត ថ្មី ។ ដូច្នេះ គាត់គួរតែមានការចាប់ផ្តើមថ្មី និងរស់នៅក្នុងជីវិតបែបថ្មីដោយស្វ័យប្រវត្តិ ។

លើសជាងនេះទៅទៀតនោះ ការសម្អា តអតីតកាលដូចនេះ ក៏មិនមែនជាក្បួនច្បាប់របស់ក្រុមជំនុំដែរ ។ ក្រុមជំនុំ គ្មានក្បួនច្បាប់ ឬសេចក្តីទាមទារយ៉ាងដូច្នេះទេ ប៉ុន្តែជីវិតដែលយើងបានទទួល គឺជាជីវិតបរិសុទ្ធ ហើយព្រះវិញ្ញាណដែលគង់នៅក្នុងយើង ទ្រង់កំពុងធ្វើចលនានិងធ្វើការងារ ដូច្នេះព្រះវិញ្ញាណនោះឯង នឹងទាមទារឱ្យយើងដកយករូបគោរពទាំងអស់ និងរឿងរ៉ាវដែលទាក់ទងទៅនឹងរូបគោរព អារក្ស និងរបស់ស្មោកគ្រោកចោលចេញ ដើម្បីស្តារឡើងវិញនូវអ្វីដែលយើងបានជំពាក់ ព្រមទាំងកាត់ចោលរបៀបរស់នៅចាស់របស់យើង ។

គំរូឧទាហរណ៍មួយអំពីការសម្អាតអតីតកាល ត្រូវបានមើលឃើញនៅក្នុងរឿងរបស់ពួកអ្នកជឿ នៅក្រុងថែស្សាឡូនីច (១ថស.១:៩)។ ការបែរចេញពីរូបគោរព មកឯព្រះជាម្ចាស់ មិនមែនគ្រាន់តែជាការបែរចេញពីរូបព្រះមិនពិត ដែលមានអារក្ស និងវិញ្ញាណអសោចនៅពី ខាងក្រោយប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការបែរចេញពីគ្រប់ទាំងអស់ ដែលជំនួសឱ្យព្រះជាម្ចាស់ផងដែរ ។ គំរូឧទាហរណ៍ទីពីរអំពីការសម្អាតអតីតកាល ត្រូវបានមើលឃើញនៅក្នុងរឿងរបស់ពួកអ្នកជឿនៅក្រុងអេភេសូរ ។ គម្ពីរកិច្ចការ ១៩:១៩ បានប្រាប់យើងថា ពួកអ្នកជឿនៅក្រុងអេភេសូរ ដែលប្រព្រឹត្តមន្តវិជ្ជាប្លែកៗ បាននាំគ្នាយកក្បួនតម្រារបស់ខ្លួនមកដុតចោល ។ នេះជាជំហានដំបូងក្នុងការអនុវត្តរបស់យើង ដែលត្រូវដុតបំផ្លាញរបស់មន្ទិលសៅហ្មង និងរបស់ស្មោកគ្រោក ឬជារបស់មិនត្រឹមត្រូវចោលចេញ ។ គំរូទីបីអំពីការសម្អាតអតីតកាល ត្រូវបានមើលឃើញនៅក្នុងរឿងរបស់សាខេ ពេលដែលគាត់សងនូវអ្វីដែលគាត់បានជំពាក់ដល់អ្នកដទៃ ។ បន្ទាប់ពីសាខេបានសង្គ្រោះភ្លាម គាត់និយាយទៅព្រះអម្ចាស់ថា បើគាត់បានហូតពន្ធបំបាត់ចំពោះនអ្នកណា នោះនគាត់នឹងសងគេ ១ជា៤វិញ

## បញ្ចប់របៀបរស់នៅចាស់

នេះមិនមែនជារឿងដែលយើងត្រូវសួរខ្លួនឯង អំពីបាបរបស់យើងនៅពេលអតីតកាលនោះទេ ប៉ុន្តែជារឿងដែលយើងត្រូវសួរខ្លួនឯងថា តើក្នុងនាមយើងជាកូនរបស់ព្រះ យើងគួរតែនៅដូចពីពេលមុនទៀត ឬខុសពីពេលមុន ។ នេះមិនមែនជាសេចក្តីបង្រៀន ប៉ុន្តែជាកិច្ចការរបស់ព្រះវិញ្ញាណបរិសុទ្ធវិញ ពីព្រោះរឿងទាំងអស់នេះ ជារឿងមនុស្សថ្មី ជាមួយនឹងការដំណើរជីវិតថ្មី ដែលគ្រប់រឿងរ៉ាវទាំងអស់នៅក្នុងការដំណើរជីវិតចាស់ត្រូវបានបញ្ចប់ ។ នេះគឺជាការសម្អាតអតីតកាល!

ដូច្នេះ ជីវិត និងសេចក្តីសុខសាន្តនេះគឺជាកម្រិតដែលតម្រូវឱ្យយើងសម្អាតអតីតកាល ។ ប្រសិនបើយើងដើរតាមការទាមទារនៃអារម្មណ៍ផ្នែកខាងក្នុង ដោយលន់តួអំពើបាប បោះបង់រូបគោរព បំផ្លាញរបស់មន្ទិលសៅហ្មងនិងរបស់ស្មោកគ្រោក សងនូវអ្វីដែលបានជំពាក់ និងបញ្ចប់របៀបរស់នៅចាស់របស់យើង នោះ យើងនឹងមានអារម្មណ៍ថា ត្រូវបានចម្រើនកម្លាំង មានពន្លឺ ស្កប់ចិត្ត និងមានជីវិតរស់ឡើងវិញព្រមទាំងមានអារម្មណ៍សុខសាន្ត សុវត្ថិភាព និងពេញដោយវត្តមានរបស់ព្រះអម្ចាស់ ។

# ជីវិតខ្ញុំបានផ្លាស់ប្រែ

(ឥ. 309)




២. ចំណងបាបបានផ្ដាច់ទៅខ្ញុំរស់នៅមានសិរី តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត
ក្ដីប្រាថ្នាក្នុងសាច់ឈាមទ្រង់បានលាងឲ្យស្អាតថ្មី តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត ។

៣. ក្ដីសប្បាយក្នុងលោកនេះប្រែជាអស់រសជាតិហើយ តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត
ទុក្ខកង្វល់ក្នុងលោកនេះមិនអាចឃាំងខ្ញុំបានឡើយ តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត ។

៤. ខ្ញុំបញ្ឈប់ចិត្តវេរា ភាពទទេក្នុងជីវិត តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត
ក្ដីសុខសាន្តនិងអំណរឲ្យចិត្តខ្ញុំស្កប់ស្កល់ពិត តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត ។

៥. រឿងអតីតបានផុតទៅមិនអាល័យផ្លូវចាស់ឡើយ តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត
ឥឡូវដើរក្នុងផ្លូវទ្រង់ក្ដីសង្ឃឹមពោរពេញហើយ តាំងពីព្រះយេស៊ូគង់ក្នុងចិត្ត ។